# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សោម លឿ ហៅ ផល I 03383
## សម្ភាសជាមួយៈ កែវ លឿ អាយុ៥៤ឆ្នាំ ជាម្ចាស់ប្រវត្តិរូប
## នៅភូមិដាំផល ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ
## ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៥
## សម្ភាសន៍ដោយៈ ដាន់ សុជា
## សរុបៈ ៣៨ទំព័រ

សុជាៈ ចុះពួកខ្ញុំម៉ោពីខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ហើយមានសរសេរសៀវភៅទស្សនាវដ្តីស្វែងរកការពិត មកជួបពូថ្ងៃនេះគឺចង់សួរនាំពូពីរឿងរ៉ាវជីវិតរបស់ពូដែរ បានឆ្លងកាត់របបខ្មែរក្រហម ដើម្បីយកទៅសរសេរជាសៀវភៅ ទុកជាឯកសារទៅថ្ងៃក្រោយដើម្បីឲ្យអ្នកជំនាន់ក្រោយគេបានដឹង ពីការរស់នៅតស៊ូលំបាកស្រណុកនៅជំនាន់ពូហ្នឹងណា?

លឿៈ បាទ!

សុជាៈ ហើយកុំឲ្យទៅថ្ងៃក្រោយទៅ ក្មេងៗដូចបានដឹងពីរបបនេះ?

លឿៈ បាទ!

សុជាៈ របបនោះស្រណុកទៅហើយក្មេងៗ ចេះថ្មីងថ្មែងរកអ្វីដែរល្អមកដឹកនាំ មកអនុវត្តន៍នៅក្នុងប្រទេស?

លឿៈ បាទ!

សុជាៈ កុំឲ្យមានបញ្ហាដូចជំនាន់ហ្នឹងទៀត ពូឈ្មោះអីដែរពូ?

លឿៈ ខ្ញុំឈ្មោះ កែវ លឿ ។

សុជាៈ កែវ លឿ?

លឿៈ បាទ!

សុជាៈ ចុះសោម លឿ នោះ?

លឿៈ ខ្ញុំហេះ ។

សុជាៈ អ៊ុត សោម ត្រកូលតាមណា?

លឿៈ ដាក់ត្រកូលចេះកាលដែរខ្ញុំនៅរៀនមានអាវ៉ែងគេឲ្យសញ្ញាបត្រគេឲ្យទិញប័ណ្ណកីឡា ។

សុជាៈ បាទ?

លឿៈ ប័ណ្ណកីឡានឹងឯងម៉ាជំនាន់សង្គមនោះយើងវាខ្វះថវិការសន្ទុត់មាត់ញក ។

សុជាៈ បាទ.?

លឿៈ ប័ណ្ណកីឡា សម្តេចឪ មួយនេះឯងគេមួយរយចូលគ្នាពីរនាក់ ។

សុជាៈ បាទ?

លឿៈ ដល់ចូលគ្នាពីរនាក់ ខ្ញុំនេះម្នាក់ប្អូននេះម្នាក់ តែស្លាប់អស់ហើយសព្វថ្ងៃ ត្រូវយកប័ណ្ណកីឡាម្នាក់ ហាសិបរៀល ដល់ចុះដាក់គោកជាមួយគ្នាទៅ ។

សុជាៈ ហើយរាល់ថ្ងៃពូឈ្មោះ កែវ លឿ នោះ?

លឿៈ បាទ!

សុជាៈ មានឈ្មោះហៅផ្សេងទៀតទេ?

លឿៈ មាន!

សុជាៈ ឈ្មោះអ្វីដែរ?

លឿៈ ឈ្មោះជំនាន់នៅក្នុងរបបបីឆ្នាំ ឈ្មោះ សុផល ។

សុជាៈ ពូអាយុប៉ុន្មានដែរមកដល់រាល់ថ្ងៃ?

លឿៈ ៥៨!

សុជាៈ ៥៨ឆ្នាំ?

លឿៈ ស្មើរនឹង សម្តេច ហ៊ុនសែន ។

សុជាៈ បាទ?

លឿៈ បាទលើសគាត់ពីថ្ងៃ ។

សុជាៈ ពីថ្ងៃ?

លឿៈ បាទ!

សុជាៈ បងថ្ងៃទៀត ៥៨ឆ្នាំនោះ ពូនៅក្នុងភូមិរាល់ថ្ងៃហៅភូមិអ្វីដែរ?

លឿៈ ហៅភូមិដាំផល ។

សុជាៈ ភូមិអីគេ?

លឿៈ ដាំផល ។

សុជាៈ ដាក់ដាំ?

លឿៈ បាទ!

សុជាៈ ដាំផល ឃុំ?

លឿៈ មានជ័យ ។

សុជាៈ ឃុំមានជ័យ?

លឿៈ បាទ!

សុជាៈ ខេត្តកំពង់ធំណាស់?

លឿៈ បាទ!

សុជាៈ ចុះកំណើតកើតជារបស់ពូនៅភូមិ ឃុំណាដែរ?

លឿៈ នៅភូមិរនាម ។

សុជាៈ ពូកើតនៅភូមិរនាម?

លឿៈ បាទ!

សុជាៈ ហើយពូមកនៅនេះតាំងពីឆ្នាំណាដែរ?

លឿៈ មកនៅត្រឹម៧៨ ។

សុជាៈ ៧៨ហេះ?

លឿៈ ក្នុងពេលដែលកប៉ាល់ហោះវៃឆេះផ្ទះ ឆេះភូមិអស់ ។

សុជាៈ រត់មកនៅណេះមក?

លឿៈ បាទ! ប៉ុន្តែខ្ញុំមកនៅណេះទេ ឪពុក ម៉ែ មកនៅណេះ ។

សុជាៈ បាទ?

លឿៈ ដល់៧៩ បានម៉ោជុំ ។

សុជាៈ ឪពុក ពូឈ្មោះអីដែរ?

លឿៈ ឈ្មោះ កែវ លាង ។

សុជាៈ កែវ លឹម?

លឿៈ  លាង ។

សុជាៈ  លាង?

លឿៈ  ចុះម្ដាយសៅ សន ។

សុជាៈ  គាត់នៅរស់ទាំងពីរ?

លឿៈ  ស្លាប់អស់ ។

សុជាៈ  ស្លាប់អស់ ពូមានបងប្អូនប៉ុន្មាននាក់ទៀត?

លឿៈ  មាន៣នាក់ ។

សុជាៈ  ៣នាក់?

លឿៈ  បាទ!

សុជាៈ  នៅរស់ប៉ុន្មាននាក់ដែរអ៊ឹ?

លឿៈ  រស់ទាំងអស់ ។

សុជាៈ  នៅរស់ទាំង៣?

លឿៈ  អាមួយធ្វើគ្រូនៅពាម ។

សុជាៈ  ពូកើតជាឆ្នាំណាដែរ?

លឿៈ  ខ្ញុំកើតឆ្នាំ៥១ ,១៩៥១ ។

សុជាៈ  ហើយគ្រួសារពូរាល់ថ្ងៃ ឈ្មោះអ៊ីដែរ?

លឿៈ  សុខ សារ៉េត ។

សុជាៈ  មានកូនចៅប៉ុន្មាននាក់ពូ?

លឿៈ  មានកូន៨នាក់ ។

សុជាៈ  រាល់ថ្ងៃពូប្រកបមុខរបបអ៊ីដែរ?

លឿៈ  ធ្វើស្រែណឹង ។

សុជាៈ  អត់មានធ្វើណេះ?

លឿៈ  បាទ!

សុជាៈ  ចុះកាលនៅពីតូចនៅកុមារណឹងពូរៀនដល់ថ្នាក់ណាដែរ?

លឿៈ  ខ្ញុំរៀនថ្នាក់ទី៣ លោកសង្ឃ ។

សុជា៖  ទី៣?

លឿ៖  ទី៣លោកសង្ឃ វាស្មើរនឹងថ្នាក់ទី៧ក្មេង។

សុជា៖  កាលជំនាន់ណឹង?

លឿ៖  បាទ!

សុជា៖  រៀនបានច្រើនដែលអញ្ចឹង?

លឿ៖  បាទរៀនសាលាបាលី ខាងលោកសង្ឃ។

សុជា៖  នៅវត្តណាពូទៅរៀន?

លឿ៖  នៅវត្តផន។

សុជា៖  វត្តផន?

លឿ៖  បាទ!

សុជា៖  ឃុំអីដែរ ភូមិអីដែរអ៊ំ?

លឿ៖  ឃុំផន ស្រុកសណ្តាន់។

សុជា៖  កាលរៀនណឹងក្រោយមកបានឈប់រៀនណឹងដោយសារមូលហេតុអីដែរ?

លឿ៖  រដ្ឋប្រហារ។

សុជា៖  រដ្ឋប្រហារឈប់រៀន?

លឿ៖  បាទ! ដល់ពេលរៀនមានល្បឿនលឿន អត់ទាន់ចង់ឈប់ ប៉ុនដល់រដ្ឋប្រហារអត់គ្រូបង្ហាត់។

សុជា៖  អស់សិស្សអី អស់គ្រូអី?

លឿ៖  អស់សិស្ស អស់គ្រូឈប់ណឹងបាទ។

សុជា៖  ហើយដល់ពេលឈប់ដែរពូធ្វើអីវិញទៅ?

លឿ៖  ធ្វើស្រែម៉ារយៈខ្វីទៅ បានស្ងួដែរ។

សុជា៖  ធ្វើស្រែបានប៉ុន្មានឆ្នាំដែរ?

លឿ៖  បានប្រហែលជា៣ខែ។

សុជា៖  បាន៣ខែ?

លឿ៖  គេបញ្ជូនឲ្យទៅមុខ។

សុជាៈ បញ្ជូនទៅមុខទៀត?

លឿៈ បាទ!

សុជាៈ ពីណាគេអ្នកបញ្ជូនទៅ?

លឿៈ អ្នកបញ្ជូនស្លាប់អស់ហើយសព្វថ្ងៃ។

សុជាៈ គាត់ឈ្មោះអីដែរ ពូចាន់?

លឿៈ មេភូមិ។

សុជាៈ មេភូមិ?

លឿៈ បាទ!

សុជាៈ នៅភូមិណាដែរ?

លឿៈ នៅភូមិបានមាន។

សុជាៈ ហើយកាលចូលដំបូងគេមកប្រាប់ត្រង់ ប្រាប់យើងថាមេចបានយើងគាត់ឲ្យគាត់ទៅ?

លឿៈ អាណឹងគេបំពាក់មនោគមវិជ្ជាមួយ សម្រាប់ឲ្យយើងសម្រាប់ក្នុងការឈឺចាប់ខាងនោះ។

សុជាៈ បាទ?

លឿៈ ថារបបជញ្ជាំងចេញចូលវា ថាយើងវាមិនដែលឃើញមិនដែលធ្លាប់ដឹង គេបំផុសពីវណ្ណៈជិះជាន់ វណ្ណៈសក្តិភូមិ រួចទៅគេឲ្យទៅបើចិត្តខ្ញុំ ខ្ញុំអត់ចង់ទៅទេ ព្រោះអ្នកបួស ប៉ុនបើមិនទៅ គេយកឪពុកខ្ញុំទៅធ្វើទារុណកម្ម។

សុជាៈ អញ្ចឹងកាលពូនៅរៀន ពូនៅជាសង្ឃទេ?

លឿៈ នៅសង្ឃ។

សុជាៈ តែដល់ពេលក្រោយមកសឹកណឹងគេបង្ខំឲ្យសឹក ឬយើងសឹកខ្លួនឯងដោយសារមូលហេតុ?

លឿៈ សឹកខ្លួនឯង ដោយសារអត់បានរៀន។

សុជាៈ អត់បានរៀនសឹក?

លឿៈ បាទ!

សុជាៈ ហើយពេលចូលមកទ័ពហ្នឹងចូលនៅឆ្នាំ៧០ ហ្នឹងដែរ?

លឿៈ ៧០។

សុជាៈ ហើយកាលពូចូលអាយុប៉ុន្មាន?

លឿ៖ ១៨ ។

សុជា៖ ចុះនៅក្នុងភូមិមានគេទៅច្រើនគ្នាដែរ?

លឿ៖ ច្រើនទៅមួយវគ្គជាមួយគ្នា ចេញ២០នាក់ជាង ២៣នាក់ ។

សុជា៖ ២៣នាក់?

លឿ៖ ចុះបាត់អស់ នៅសល់៣នាក់សព្វថ្ងៃ ។

សុជា៖ ចុះគ្រួសារពូ ដូចថាបងប្អូនអី មានអ្នកត្រូវរបួសអីដែរទេពូ?

លឿ៖ អត់ ។

សុជា៖ ត្រូវតែពូម្នាក់ទេ?

លឿ៖ បាទ!

សុជា៖ កាលទៅដំបូងគេឲ្យទៅកន្លែងណា?

លឿ៖ មុនដំបូងគេបញ្ជូនឲ្យទៅស្រុក ។

សុជា៖ ស្រុកសណ្ដាន់ណឹង?

លឿ៖ បាទ!

សុជា៖ គេឲ្យធ្វើអីដែរ?

លឿ៖ នៅស្រុកហាត់បានពីខែ គេឲ្យខ្ញុំចេញបន្ទាត់ បន្ទាត់អាវឿងទព័ថ្មី រហូតដល់៧១ខ្ញុំមានជំងឺធ្ងន់សុំគេមកសម្រាកផ្ទះ ដល់មកអ្នកស្រុកគេអត់និយាយរក អត់និយាយរកខ្ញុំទៅបណ្ដោយទៅមុខ ។

សុជា៖ ចុះពូទៅដំបូងគេឲ្យហាត់សិន?

លឿ៖ បាទ!

សុជា៖ ឲ្យហាត់ៗ ហើយបានគេបន្ទាត់ គេឲ្យពូបន្ទាត់គេវិញ ។

លឿ៖ បាទ! បន្ទាត់តគ្នា ។

សុជា៖ អ៎! ទព័ថ្មីណោះ?

លឿ៖ បាទ! បន្ទាត់ ។

សុជា៖ អញ្ចឹងពូមានជំងឺអីបានមកផ្ទះវិញ?

លឿ៖ គ្រុនចាញ់ ។

សុជាៈ ហើយនៅផ្ទះបានប៉ុន្មានខែ?

លឿៈ នៅបាន៣ខែ ។

សុជាៈ មូលហេតុអីបានពូនិយាយមិញថាអ្នកភូមិ គេអត់និយាយរក?

លឿៈ ព្រោះយើងទៅមុខហើយមកវិញ គេអត់និយាយរកទេ អ្នកសមរភូមិក្រោយគេស្រាច់តែយើងដាច់ខាត ធ្វើមេទិញក្រោយណាណឹងគេអត់ហៅយើងចូលរួមទេ គេទុកឡែកោះនៅតែឯងទៅ រស់នៅជាមួយក្នុយស្រុកក្រៅ ។

សុជាៈ ចុះបងប្អូនយើងអីដូចថា អ្នកភូមិមិនមែនប្រធានភូមិ ប្រធានឃុំគេនិយាយរកយើងធម្មតា

លឿៈ និយាយរកប៉ុន្តែ អត់មានពួកទេ ។

សុជាៈ បាទ?

លឿៈ បងប្អូនគេដូចតូចក្តី ធំក្តីនិយាយជាមួយគ្នាធម្មតា ។ ដល់គ្មានពួកទេគេអត់និយាយ ។

សុជាៈ អត់មានពួកអ្នក ៗ ធ្វើការងារ ស្រុកភូមិហ្នឹងគេអត់រាប់រកយើងទេ?

លឿៈ គេអត់រាប់ ។

សុជាៈ ចុះក្រោយពូទៅទៀត?

លឿៈ បាទ!

សុជាៈ ទៅតាមណាវិញ?

លឿៈ ទៅជិវ១០, ១១ ឋិតនៅទ័ព្ទរមុខ ដែលចូលសមរភូមិហើយ ។

សុជាៈ ឈ្មោះវា ឈ្មោះដី ?

លឿៈ បាទ!

សុជាៈ នៅនៅណា គាត់ធ្វើទ័ពនៅណា?

លឿៈ ស្រុកកំណើតគាត់នៅវាលព្រីង ។

សុជាៈ អ៎! តែគាត់?

លឿៈ នៅដួរ នៅទ័ពកំពង់ធំ ។

សុជាៈ បាទគាត់ឋានៈអីដែរ?

លឿៈ អនុកងតូច ។

សុជាៈ ក្នុងកងពលអីដែរ?

លឿៈ ៣១០ ។

សុជាៈ ឈរជើងនៅម្តុំណាហ្នឹង?

លឿៈ នៅលុងលោក ។

សុជាៈ លុងលោកហ្នឹងឃុំអី ស្រុកអី ខេត្តអីដែរ?

លឿៈ ស្រុកកំពង់ស្វាយ ។

សុជាៈ ស្រុកកំពង់ស្វាយ?

លឿៈ បាទ!

សុជាៈ ខេត្តកំពង់ធំយើងហ្នឹង?

លឿៈ បាទ!

សុជាៈ ហើយទៅនៅមុនដំបូងទៅនៅធ្វើអីនៅហ្នុង?

លឿៈ នៅទៅមុនដំបូងគឺយើងមិនទាន់ចូលដល់ខាងទព័ថ្មី គេឲ្យហ្វឹកហ្វឺនរៀនសូត្រជាការវ៉ៃតប់ ប៉ុន្តែថា ខ្ញុំវាអត់ពិបាករៀនប៉ុន្មានព្រោះខ្ញុំចេះទៅពីណោះ ហើយទៅដល់គេបំពាក់កាំភ្លើងចុះត្រៀមប៉ុណ្ណឹង ។

សុជាៈ ពួចុះទៅគេឲ្យមានឋានៈអីដែរ?

លឿៈ នៅៗ ។

សុជាៈ នៅយុទ្ធជន?

លឿៈ បាទ! យុទ្ធជន ។

សុជាៈ ឡើងស្គាល់ភូមិមុនដំបូង ឡើងមកភូមិណាដែរ?

លឿៈ ឡើងមកភូមិហ្នឹងមុនដំបូងឡើងដេសែប ។

សុជាៈ ដេសែប?

លឿៈ ដេសែប, ប្រម៉ាត់ដី, អូក្អែកព, សាន់គ, រលួស ខ្ញុំមានឋានៈជាការំប៉ូស្សុងអស់ក្រុម ។

សុជាៈ អស់ក្រុម?

លឿៈ បាទ!

សុជាៈ អនុហើយប្រធានកងតូចហ្នឹងគ្នាប៉ុន្មាននាក់ដែរយើងគ្រប់គ្រង?

លឿៈ ៣០ ។

សុជាៈ ៣០នាក់?

លឿៈ បាទ!

សុជាៈ អាហ្នឹងវ៉ៃជុំវិញទីក្រុងកំពង់ធំហ្នឹងណេះ?

លឿៈ បាទ!

សុជាៈ ចុះដល់ពេលឆ្នាំ អាហ្នឹងពូនៅកងពល៣១០ហ្នឹងដែរ?

លឿៈ បាទ!

សុជាៈ ពីណាគេប្រធានកងពលមានស្គាល់ទេ?

លឿៈ ណេ៎តា យានៗ

សុជាៈ តា យានហេះ?

លឿៈ តាសំបូ ប្រធានវរៈ, តាយាន អនុប្រធានៗ

សុជាៈ ចុះប្រធានកងពល?

លឿៈ ប្រធានកងពល តាអឿន អនុកងពល ខុនៗ

សុជាៈ កងវរៈលេខប៉ុន្មាន សំបូហ្នឹង?

លឿៈ អ៎ា! ៣១៧ៗ

សុជាៈ សេនាធំ សេនាតូច?

លឿៈ វរសេនាតូច៣១៧ៗ

សុជាៈ ម៉េចទៅ?

លឿៈ ចុងឆ្នាំ១៩៧៣ ត្រូវបានទទួលការតាំងឲ្យខ្ញុំទៅគូលែនៗ

សុជាៈ ទៅណា?

លឿៈ ទៅគូលែនៗ

សុជាៈ គូលែនណា?

លឿៈ គូលែន ភ្នំគូលែនៗ

សុជាៈ អ៎?

លឿៈ សៀមរាបៗ

សុជាៈ ចុង៧៣?

លឿៈ បាទ! ចុង៧៣ ។

សុជាៈ ពីណាគេឲ្យពូទៅ?

លឿៈ ទៅជាមួយប្រធានវរៈ អនុប្រធានវរៈ ។

សុជាៈ សំបូ អីហ្នឹង?

លឿៈ បាទ! ទៅទទួល សម្តេចសីហនុ ព្រះអង្គយាងចូលមកនៅភ្នំគូលែន បេសកម្មមួយអាទិត្យ នៅកន្លែងនេះ បានវិលមកកាន់កន្លែងដើមវិញ ។

សុជាៈ ចុះទៅៗ ទៅទទួលសម្តេចឪ ចេញមកពីខាងណាវិញ?

លឿៈ មកពីប៉ៃកំាង ។

សុជាៈ ប៉ៃកំាងវិញ ចុះគាត់ឆ្លងតាមណា?

លឿៈ តាមទល់ដែន ។

សុជាៈ ទល់ដែនថៃ?

លឿៈ បាទ!

សុជាៈ ហើយចូលមកតាមភ្នំគូលែន?

លឿៈ បាទ!

សុជាៈ បោះទីតំាងនៅហ្នឹងទៅ?

លឿៈ បោះទីតំាងនៅបីថ្ងៃបានយាងទៅវិញ ហើយទព័យើងក៏វិលទៅកាន់កន្លែង ។

សុជាៈ ព្រះអង្គយាងទៅណាវិញដែរ?

លឿៈ ទៅប៉ៃកំាងវិញ ។

សុជាៈ ទៅប៉ៃកំាងវិញ នៅពេលដែលមកដល់ សម្តេចសីហនុ គាន់និយាយរឿងអីខ្លះដែរ មុនទទួលគាត់ដែរ?

លឿៈ ពេលដែលព្រះអង្គមក ព្រះអង្គសួរសុខទុក្ខកូនចៅហើយឲ្យកូនចៅខំប្រឹងប្រែងតស៊ូវៃ ចក្រពត្តិអាមេរិក, នល់ នល់ ដែលបានហើយ បរាជ័យទៅចាប់សភាពឡើងដូចមុន ។

សុជាៈ ឲ្យដូចសម័យគាត់?

លឿៈ ដូចសម័យសង្គមរាស្ត្រនិយម ។

សុជាៈ ហើយគាត់មាននិយាយថា បន្ទាប់ពីឈ្នះ យើងឈ្នះលន់ នល់ ទៅអ្នកណាដែលត្រូវឡើងគ្រប់គ្រងអំណាច?

លឿៈ បាទ!

សុជាៈ គាត់មាននិយាយទេ?

លឿៈ ព្រះអង្គនិយាយច្រើនដែរពេលណាដែរយើងវ៉ៃឈ្នះចក្រពត្តិអាមេរិក យើងរៀបស្រុកភូមិយើងឲ្យដូចកាលពីនៅមុន មិនឲ្យកូនចៅធ្វើសង្គ្រាមអីតទៅទៀត ។

សុជាៈ ហ្នឹងហើយ?

លឿៈ ឲ្យបានសុខសាន្តពេលនេះទៅ ខ្លាចវាត្រឡប់មវិលមកវិញនៅឆ្នាំ១៩៧៤ ដើមឆ្នាំនៅថ្ងៃ ១៥ ខែ១ ៧៤ ស្នងការកងធំ ។

សុជាៈ ថ្ងៃប៉ុន្មានថ្ងៃ?

លឿៈ ថ្ងៃ១៥-២១ ។

សុជាៈ ៧៤?

លឿៈ ៧៤ ។

សុជាៈ ស្នងការអីគេហ្នឹង?

លឿៈ ស្នងការប្រធានកងធំ ។

សុជាៈ ស្នងការកងធំមក?

លឿៈ បាទ!

សុជាៈ គ្នាប៉ុន្មាននាក់កងធំហ្នឹង?

លឿៈ កងធំត្រួតពាកងតូច មានគ្នា១២០ មេទព័ក៏២០ ។

សុជាៈ ហ្នឹងប្រធានស្នងការហ្នឹង?

លឿៈ បាទ!

សុជាៈ ដល់ពេលពូត្រួតហ្នឹងពូ ទៅនៅម្តុំណាកាលហ្នឹងឈរជើងនៅណាដែរ?

លឿៈ នៅសន្ទុក ។

សុជាៈ នៅក្នុងកងពលដែទេ?

លឿៈ បាទ!

សុជាៈ វរសេនាតូចដែរ?

លឿៈ វរសេនាតូចដែរ ។

សុជាៈ ៣១០អីប៉ុន្មាន?

លឿៈ បាទ!

សុជាៈ វរសេនាតូចលេខប៉ុន្មាន?

លឿៈ ៣១៧ ។

សុជាៈ ៣១៧ ហើយចុះពេលណា ដែលពូឡើងទៅវៃនៅសមរភូមិនៅភ្នំពេញ?

លឿៈ នៅភ្នំពេញ?

សុជាៈ បាទ?

លឿៈ ក្រោយពេលដែលចាត់តាំងពី ស្មនការកងធំហើយដកទៅភ្នំពេញ បេសកម្មនៅកំពង់ស្ពឺរយៈវែង ។

សុជាៈ ប្រហែលជាប៉ុន្មានឆ្នាំ?

លឿៈ ប្រហែលជា៣ខែជាង នៅសៀមរាប ឬទៅកំពង់ស្ពឺ ។

សុជាៈ ដល់ទៅឈរជើងនៅកំពង់ស្ពឺហ៎?

លឿៈ បាទ!

សុជាៈ នៅម្តុំណាកំពង់ស្ពឺ?

លឿៈ នៅម្តុំវង់កេ កាណាតពង បែកចាន ខាងលិច២៦ ។

សុជាៈ ទៅធ្វើអីនៅហ្នឹង?

លឿៈ ទៅវៃទាហាន ។

សុជាៈ ទៅវៃទាហាន លន់ នល់?

លឿៈ បាទទៅវៃទាហាន ។

សុជាៈ រយៈពេលប៉ុន្មានខែដែរពូ?

លឿៈ ៣ខែ ។

សុជាៈ ក្នុងឆ្នាំ៧៤ហ្នឹង?

លឿៈ បាទ!

សុជាៈ ចុះដល់ពេលទៅវៃហ្នឹង អើដូចថាបានទទួលជ័យជំនះច្រើនទេ?

លឿៈ ហ៊ើជ័យជំនះ នឹង បរាជ័យស្មើរគ្នាបាទ ។

សុជាៈ ត្រូវចាញ់ៗត្រូវ?

លឿៈ ត្រូវឈ្នះៗកន្លែងនឹង ។

សុជាៈ អើចុះបន្ទាប់ពី៣ខែហ្នឹងមក?

លឿៈ កងទ័ពប្រមូលពីកំពង់ធំវិញ ។

សុជាៈ វៃនៅណា?

លឿៈ វិលមកកំពង់ធំ ឈរជើងនៅកំពង់ធំ វៃអើសេនាតូច រលួស ។

សុជាៈ វៃយើង រលួសយើងជិតកំពង់ធំហ្នឹងនេះ?

លឿៈ បាទ!

សុជាៈ ចុះដល់ពេល?

លឿៈ រហូតដល់ដាច់ឆ្នាំគ្រាន់ថាថ្ងៃ៥ ខែ១២, ៧៨ ខ្ញុំបាទទទួលឋានៈជាអនុប្រធានកងវរសេនាតូច ។

សុជាៈ ថ្ងៃ១០ប៉ុន្មាន?

លឿៈ ថ្ងៃ១៥ ។

សុជាៈ ថ្ងៃ១៥ ខែ១២ ៧៨ ឡើងជាអីគេ?

លឿៈ អនុវរៈ ។

សុជាៈ សេនាតូច?

លឿៈ បាទ!

សុជាៈ ចុះអាហ្នឹងឡើងជិតស្មើរជាមួយតាសំបូ?

លឿៈ បាទ! តាសំបូ ក្បត់បាត់ហើយគេបាញ់ចោល ។

សុជាៈ គេបាញ់ចោល មូលហេតុអីបានក្បត់?

លឿៈ មិនដឹងរមិចទេ គេហៅទាហានឲ្យមកពទ្ធ័ផ្ទះយើងវរសេនាតូចនៅម្តុកបាត់ទៅទេ ។

សុជាៈ នៅអាជិតយើង?

លឿៈ ដូចរលួសកើតរលួសបាទ ។

សុជាៈ ចុះពីណាគេបាញ់សម្លាប់?

លឿៈ តាគីម ។

សុជាៈ តាគីមហេះ ចុះតាគីមឡើង អើតាគីមអនុៗ?

លឿៈ អនុវរៈ ។

សុជាៈ កងពល៣?

លឿៈ អនុវរៈ ។

សុជាៈ អនុវរៈរបស់តាសំបូហ្នឹង?

លឿៈ អនុ សំបូ ។

សុជាៈ បាញ់តាសំបូ ហ្នឹងចោលទៅ?

លឿៈ បាទ!

សុជាៈ ហើអាកាលដែរសំបូ ក្បត់ហ្នឹងវាមានរឿងរ៉ាវម៉េចពូអាចនិយាយប្រាប់ខ្ញុំតិចបានទេ?

លឿៈ ខ្ញុំក៏មិនអាចដឹងបានទេ ព្រោះកាលណោះខ្ញុំមិនទាន់ចូលក្នុងការគ្រប់គ្រងណាស់ ។

សុជាៈ បាទ?

លឿៈ ព្រោះវានៅជាដូចនៅជាកូនទ័ពគេប៉ុន្តែក្រោយមកខ្ញុំដឹងថា គាត់អ្នកក្បត់យកទ័ពមកពទ្ធ័ឯង គាត់ក្បត់ហើយគាត់ចូលដៃចូលជើង ជាមួយទាហាន លន់ នល់ ។

សុជាៈ បាទ?

លឿៈ បាទ! បានចាប់បានគេអូ អញ្ចឹងគេក៏សម្លាប់គាត់ចោលទៅហើយតាគីម គាត់ក៏ឡើងឋានៈ ទៅ ហើយបានខ្ញុំឡើងបន្តរគាត់ទៀត ហើយក្រោយពេលដែលចាត់តាំងជាអនុសេនាតូច ហើយ គឺត្រូវនាំទ័ពទៅវៃភ្នំពេញ ។

សុជាៈ វៃភ្នំពេញ?

លឿៈ វៃភ្នំពេញនៅឆ្នាំ៧៥ ។

សុជាៈ ចុះពេលគេបាញ់តាបូ ចោលនៅកន្លែងណា?

លឿៈ នៅភ្នំសន្ទុក ។

សុជាៈ ភ្នំសន្ទុក គេចាប់ៗ?

លឿៈ អត់ចាប់ ទេដេកអង្រឹង ។

សុជាៈ  ដេកអង្រឹង?

លឿៈ  បាទ!  ដេកអង្រឹង ។

សុជាៈ  គេចាប់តេអូបានតាបូ  គេនិយាយថាម៉េច?

លឿៈ  ឲ្យទាហានចេញទ័ព  ទ័ពរំដោះ ។

សុជាៈ  ពេល ៗ ហ្នឹងពូមានបានដឹងព្រឹត្តការណ៍  ដែលទាហានដឹកកងទ័ពរបស់ប៉ុល  ពត  ហ្នឹង?

លឿៈ  នៅពេលនោះខ្ញុំមិនទាន់ទេព្រោះ  ខ្ញុំអត់មានទៅរកស្នាក់ពីកងធំរត់ទាន់មានទេណាស់ ។

សុជាៈ  បាទ!  ដល់ពេលទៅពទ្ធ័គាត់  ទ័ពរបស់ពីណាគេ?

លឿៈ  តាខ្ញុំនិងឯងក៏នៅក្នុងអឹមសេវ៉ាតគេដែរកាលហ្នឹង?

សុជាៈ  នៅ ៗ ក្នុងការពទ្ធ័ហ្នឹងដែរ?

លឿៈ  ប៉ុន្តែខ្ញុំរត់ចេញរួច  ប៉ុន្តែមានស្លាប់ច្រើន  ស្លាប់ស្ទើរតែអស់កាលហ្នឹង  ចូលសមរភូមិ ។

សុជាៈ  មានស្គាល់ពូសយ?

លឿៈ  បាទ!

សុជាៈ  ស្គាល់ពូសយ?

លឿៈ  សយ ។

សុជាៈ  សយនៅយើងតាព្រាប  សន្ទុក?

លឿៈ  អត់ស្គាល់ទេ ។

សុជាៈ  អត់ស្គាល់ទេ?

លឿៈ  អាហ្នឹងគឺឈ្មោះសង្វាត់គាត់  ឈ្មោះអី?

សុជាៈ  បាទ!ហើយ ៗ  ទ័ព ៗ អើ  លន់  នល់  មកពទ្ធ័  ទ័ពប៉ុល  ពត  ជាប់នឹងអើពទ្ធ័ពីស្ពាម៉ាន  អីស្ពាម៉ាន  ហេតុអីបានទ័ព  ប៉ុល  ពត  អត់ដឹងខ្លួន?

លឿៈ  គេពទ្ធ័ចេញពីក្រោយមកវិញ      ពទ្ធ័ចេញពីបឹងរាវមកពទ្ធ័ពីក្រោយហើយយើងបំរុងវ៉ៃសិនអញ្ចឹងបានមិនទាន់បានវ៉ៃផង  គេវ៉ៃយើងពីក្រោយបាត់  ពទ្ធ័ជុំវិញបាត់ ។

សុជាៈ  ស្ពាម៉ានបាន ៗ ទ័ព  លន់  នល់  មកវ៉ៃទ័ពប៉ុល  ពត  ?

លឿៈ  ចុះនៅម៉ោង៨ ។

សុជាៈ  ៨ភ្លឺ?

លឿៈ បាទម៉ោង៤ភ្លឺ ។

សុជាៈ ដល់ពេលប៉ុន្មានថ្ងៃបានគេបាញ់ប៉ូ ហ្នឹងចោល?

លឿៈ បាញ់ល្ងាចហ្នឹង ។

សុជាៈ ល្ងាចហ្នឹងម៉ោង គេចាប់គេអូបាន?

លឿៈ ចាប់គេអូបាន ។

សុជាៈ ខាងណាអ្នកចាប់បាន?

លឿៈ ខាងសេនាធិការ ។

សុជាៈ ខាងសេនាធិការ?

លឿៈ បាទចាប់បានគេវៃបាញ់ចោល ។

សុជាៈ អញ្ចឹងមានដឹងថាប៉ូ មានជាប់ពាក់ព័ន្ធអីជាមួយទាហ៊ាន លន់ នល់ នៅខាងក្នុងទេ?

លឿៈ គេដឹង ។

សុជាៈ គេដឹងថាម៉េច?

លឿៈ គេដឹងថាគាត់ហ្នឹងខ្សែរយៈរបស់លន់ នល់ ។

សុជាៈ ចុះគាត់មានបងប្អូនពូ អ៊ំ អីគាត់ធ្វើការក្នុងទាហានលន់ នល់ខេត្តកំពង់ធំអីមានដឹងទេ?

លឿៈ គាសំបូរ រឿងនេះខ្ញុំមិនច្បាស់បើមិនច្បាស់ ខ្ញុំមិនហ៊ាននិយាយទេណា ព្រោះខ្ញុំនិងគាត់ក៏មិនសូវស្គាល់គ្នាច្បាស់ ស្គាល់ដោយសារក្នុងជួរទ័ពរបស់គាត់ ត្រង់បងប្អូនគាត់មានប៉ុន្មានយើងអត់ដឹងប្រវត្តិរូបរបស់គាត់ទេ ហើយពេលនោះអ្នកធំកាន់ប្រវត្តិរូបយើងអ្នកតូចជាងគេហើយបើគាត់ធំជាងយើងមិនដឹងប្រវត្តិរូបគាត់យ៉ាងណា ។

សុជាៈ ចុះពូពេលគេបញ្ជូនពូទៅវៃភ្នំពេញ ពូមានឈរជើងវៃចូលហ្នឹងដែរ?

លឿៈ មុនដំបូងខ្ញុំទៅនៅស្ពានសគ្គា ។

សុជាៈ ស្ពានសគ្គាយើងព្រែកក្ដោ?

លឿៈ បាទ! ហើយចូលទៅវៃទឹក ភូមិធំ ស្វែង បេសកកម្មបានមួយអាទិត្យខ្ញុំក៏របួសពិការ ។

សុជាៈ ត្រូវចំកន្លែងណា?

លឿៈ ត្រូវជើងបែកឆ្អឹង ខ្ញុំទៅសម្រាកពេទ្យមួយឆ្នាំ៧/៥ហ្នឹង ។

សុជាៈ ចុះឋានៈពូ?

លឿះ ឋានៈពេលនោះនៅជាប្រធានវរៈ ។

សុជាៈ ទោះត្រូវរបួសក៏ដោយ ដេកពេទ្យប៉ុន្មានឆ្នាំ ប៉ុន្មានថ្ងៃដែរ?

លឿះ ដេកពេទ្យ៦ខែ ។

សុជាៈ ពេទ្យណា?

លឿះ ពេទ្យអូរក្រវ៉ាន់គេបញ្ជូនមកអូរក្រវ៉ាន់ហ្នឹង វែងឆ្ងាយណាស់ដំបូងគេបញ្ជូនទៅភូមិក្រសាំង កំពង់ស្ពឺ ។

សុជាៈ ពេលដែលរបួសហ្នឹងគេបញ្ជូនទៅកំពង់ស្ពឺវិញ?

លឿះ បាទ!

សុជាៈ ទៅប៉ុន្មានថ្ងៃទៅ?

លឿះ ទៅនៅនោះបាន២ខែ បានគេបញ្ជូនមកភូមិភាគនេះ អូរក្រវ៉ាន់ ។

សុជាៈ នៅកំពង់ស្ពឺ គេឲ្យនៅពេទ្យមុំណាដែរ?

លឿះ ពេទ្យ២ ។

សុជាៈ នៅភូមិអី ឃុំអី?

លឿះ ភូមិក្រសាំង ។

សុជាៈ ស្រុកអីគេទៅ?

លឿះ មិនស្គាល់ដែរស្រុក ស្គាល់តែភូមិក្រសាំងព្រោះកាលហ្នឹងយើងអត់មានដែលដើរលេងតាមស្រុក តាមភូមិបានហើយខ្ញុំនោះដើរមិនរួចផង ។ កាលហ្នឹងគេបញ្ជូនមកអូរក្រវ៉ាន់ ស្រុកបារាយណ៍ ។

សុជាៈ មកដេកហ្នឹងរហូតដល់ពេលណាដែរ?

លឿះ រហូតដល់ខែ៦ ។

សុជាៈ ឆ្នាំណា?

លឿះ ឆ្នាំ៧៥ បានខ្ញុំវិលទៅភ្នំពេញ ទៅរកអន្តភាព ។

សុជាៈ អ៊ីចឹងក្នុងកំឡុងប៉ុល ពត បានជ័យជំនះវៃចូលភ្នំពេញហ្នឹងពូអត់បានចូលទៅជាមួយគេទេ របួសបាត់ហើយ ។ ចុះកាលសម្រាកព្យាបាលហ្នឹង ការព្យាបាលគេថែទាំដិតដល់ដែរ?

លឿះ ធម្មតាទេ ថែទាំកាលហ្នឹងព្រោះយើងធ្វើទ័ពកាលនោះការខុបត្ថម្ភ វាសម្រាលចេះតែរស់ ។

សុជាៈ ចុះពូទៅនៅអង្គភាពវិញ?

លឿៈ អង្គភាពគេចាត់តាំង ថ្មីទាំងអស់ ។

សុជាៈ នៅក្នុងកងពលណាដែរ?

លឿៈ កងពល៣១០ ប៉ុន អង្គភាពគេដូរថ្មីទាំងអស់មានសមាសភាពដឹកនាំគ្រប់គ្រាន់ ។

សុជាៈ ចុះពូទៅឋានៈអីដែរ?

លឿៈ គេឲ្យនៅសម្រាកមួយកន្លែងអត់ឲ្យធ្វើអីទេ បាន២ខែគេឲ្យទៅនៅជាមួយតាគឹម អនុកងពល

សុជាៈ ទៅនៅមានឋានៈអីដែរ?

លឿៈ មិនទាន់មានឋានៈនៅឡើយទេ នៅក្នុងនាមជនពិការ បានថាគេគាំទ្រការរស់នៅរហូតមក ដល់មក ។

សុជាៈ កាលហ្នឹងតាគឹម ឡើងអនុកងពល?

លឿៈ បាទ!

សុជាៈ អនុរបស់ អឿន ។

លឿៈ បាទ!

សុជាៈ ហើយឋានៈពូអត់មានទេ?

លឿៈ នៅឡើយទេ ។

សុជាៈ ពេលណាបានឲ្យឡើង?

លឿៈ ៧៦ គេបង្កើតអង្គភាព ក៨ អង្គភាពក៨សម្រាប់អ្នកពិការ គេឲ្យក្តាប់អ្នកពិការដូចគ្នា នៅពេលនោះខ្ញុំបានទទួលឋានៈជាកងធំ ។

សុជាៈ កងធំក៨ ។ នៅម្តុំណាដែរ?

លឿៈ នៅឃ្លាញ ។

សុជាៈ អត់នៅភ្នំពេញទេ?

លឿៈ បាទ!

សុជាៈ ចុះធ្វើអីគេពិការ?

លឿៈ ធ្វើកងធំ ប៉ុន្តែធ្វើស្រែដូចយើង ។

សុជាៈ អ្នកពិការអាចទៅធ្វើស្រែបានអ្នកពិការអីទៅ?

លឿៈ ពិការដៃជើងល្មមៗអាចធ្វើបានគេឲ្យធ្វើ ខ្ញុំនៅមួយកន្លែង ។

សុជាៈ ដែលគេឲ្យធ្វើអីផ្សេងទៀតទេ?

លឿៈ ធ្វើការងារគេអាចធ្វើបាន ។

សុជាៈ ចុះពូនៅកន្លែងកងពិការហ្នឹង នៅរហូតហ្នឹង ឬនៅដល់ឆ្នាំណា?

លឿៈ នៅវែងឆ្ងាយទៀតណាស់ ហើយកោះធំអីហ្នឹងក្រោយការដឹកនាំរបស់តាទី ទៀត ។

សុជាៈ តាទី?

លឿៈ តាទីប្រធានវរៈ រហូតមកដល់៧៧ ។

សុជាៈ ចុះ៧៧មកទីណាវិញ?

លឿៈ ក្នុងអំឡុងឆ្នាំ៧៧ពាក់កណ្តាលឆ្នាំក៏មានការរំដើបរំដួលចាប់ កម្មាភិបាល ។

សុជាៈ ចាប់កម្មភិបាលក្នុងកងពលណាដែរ?

លឿៈ កងពល៣១០ ។

សុជាៈ មូលហេតុអីបានគេចាប់?

លឿៈ គេថាកងពលក្បត់គេចាប់ប្រធានកងពល អនុកងពល វរៈសេនាធំអស់នោះ ។

សុជាៈ តាគីម, តាអឿនគេចាប់អស់ហើយ?

លឿៈ គេចាប់អស់ហើយនោះ ។

សុជាៈ ចុះពូដែលត្រូវកងពិការ?

លឿៈ ខ្ញុំនៅកងពិការមេៗគេចាប់អស់ទៅហើយ ខ្ញុំគេឲ្យឡើងជាអនុវរៈតទៅទៀតក្តាប់នៅកងពិការហ្នឹង ។

សុជាៈ ៧៧ហ្នឹង?

លឿៈ ពាក់កណ្តាលឆ្នាំ៧៧ ។

សុជាៈ អនុវរៈ?

លឿៈ ឡើងអនុវរៈ ។

សុជាៈ ហើយតាទី គេចាប់បាត់ហើយ?

លឿៈ ចាប់បាត់ហើយ ។

សុជាៈ ហើយពីណាមកដឹកនាំជាប្រធានវរៈវិញ?

លឿៈ នៅបន្ទាយ ។

សុជាៈ អ្នកស្រុកអ្នកភូមិខាងណាដែរ?

លឿៈ សីនៅកំពង់ចាម ។

សុជាៈ គាត់ពិការដូចគ្នាដែរ?

លឿៈ ពិការដូចគ្នាដែរ ប៉ុន្តែគាត់ដៃជើងគាត់រឹងជាងខ្ញុំ ។

សុជាៈ ចុះដល់ពេលឡើងអ៊ីចឹង គេឲ្យធ្វើការងារយ៉ាងម៉េច?

លឿៈ ធ្វើការធម្មតា ។

សុជាៈ នៅកន្លែងកប់ស្រូវហ្នឹង ធ្វើស្រូវដដែល?

លឿៈ ធ្វើស្រែ ធ្វើស្រូវដដែល មកដល់ខែ១២, ៧៧ត្រូវគេចាប់មួយសារទៀត ។

សុជាៈ ពូ?

លឿៈ ពួកខ្ញុំគេយកទៅដាក់បង្កើតជាអង្គភាពថ្មី ៣១៧ ។

សុជាៈ នៅកន្លែងណា?

លឿៈ នៅកប់ស្រូវ ។

សុជាៈ ហ្នឹងគេឲ្យធ្វើការដូចមុន?

លឿៈ ធ្វើការធ្ងន់ជាងមុន ព្រោះខ្មែរកម្មាភិបាលពីមុនគេឲ្យលត់ដំ ។

សុជាៈ ហ្នឹងគេចាប់បន្តពីអឿន, គឺមអីហ្នឹងមក?

លឿៈ បាទ! ប៉ុន្តែគេមិនទាន់ចាប់ដាក់គុក ដាក់ច្រវ៉ាក់ជង គ្រាន់ធ្វើការអត់មានម៉ោងឈប់ ក្រោកពីម៉ោង៣ ម៉ោង១សៀលបានហូបបាយព្រឹក ។ ហើយម៉ោង១០យប់បានហូបបាយល្ងាច នៅពេលនោះគឺវេទនាខ្លាំងណាស់ស្ទើរតែមិនរស់ មានបងប្អូនខ្លះបាក់កម្លាំងរហូតដល់ដើរដួល ក៏មានដែរ ហើយនៅពេលនោះ៦៨ ។

សុជាៈ ពូមានដឹងបញ្ជាដែលមកឲ្យចាប់ក្នុងកងរបស់ពូហ្នឹង ពីខាងណាគេមកបញ្ជាឲ្យចាប់ហ្នឹង?

លឿៈ មកពីប៉ុល ពត ។

សុជាៈ ហើយអ្នកដែលគេមកចាប់ហ្នឹង មិនមែនអ្នកដែលធ្វើការមជ្ឈឹមហ្នឹង មិនដែលឃើញក្នុងអង្គភាពយើង៣១០ហ្នឹង អត់ដែលឃើញ?

លឿៈ អត់មានទេ ។

សុជាៈ គេជិះអីមកចាប់?

លឿៈ ជិះឡានៗមានសញ្ញាគេភ្លើងខៀវ ក្អែកឡានគេលាប់ថ្នាំខៀវឲ្យតែឡានហ្នឹងមកមានរឿង ហើយហៅដាក់ៗហ្នុង ។

សុជាៈ អត់មានចាប់ចង ភ្ជង់វ៉ៃអីទេ?

លឿៈ អត់ទេ ។

សុជាៈ គេប្រាប់ថាម៉េចពេលគេចាប់ហ្នឹង?

លឿៈ គេមកហៅដាក់ឡាន ទៅបាត់ៗមិនដឹងទៅត្រង់ណា ។

សុជាៈ ចុះពូនៅធ្វើការហ្នឹង អត់មានផ្លាស់ប្តូរអីទៀត?

លឿៈ នៅមានទៀត ។

សុជាៈ ទៅដល់ណាទៀត?

លឿៈ ថ្ងៃ១៥ខែ១ គេបញ្ជូនខ្ញុំទៅកំពង់ឆ្នាំង ។

សុជាៈ ៧៨?

លឿៈ ១៥ ខែ១ ៧៨ គេបញ្ជូនទៅកំពង់ឆ្នាំង ។

សុជាៈ ទៅធ្វើអីដែរកាលហ្នឹង?

លឿៈ ទៅធ្វើព្រលានយន្តហោះ ។

សុជាៈ បញ្ជូនទៅ បញ្ជូនតែពូទៅឬក៏អគ្គភាពទាំងអស់គេបញ្ជូនទៅដែរ?

លឿៈ មានច្រើនដែរ ប៉ុន្តែគេដកត្រង់នេះមួយ នោះមួយទៅខាងក្រោម ទៅរាប់ពាន់នាក់សុទ្ធតែចាស់ៗទាំងអស់ ។

សុជាៈ ទៅដល់ហ្នឹងព្រលានហ្នឹងធ្វើហើយបានច្រើនដែរ ឬទើបធ្វើថ្មី?

លឿៈ គេធ្វើបានពាក់កណ្តាល ។

សុជាៈ ទៅធ្វើព្រលានហ្នឹងរហូតដល់បែក៧៩?

លឿៈ បាទ! ប៉ុន្តែខ្ញុំទៅធ្វើព្រលានហ្នឹងឯងខ្ញុំនៅបានរយៈពេល២ខែជួបពួកម៉ាកមួយហើយ ពួកម៉ាក ហ្នឹងនៅក្នុងភូមិភាគបញ្ចឹម ឈ្មោះដាន អាយុប្រហែលគ្នាគេហៅតាៗទាំងអស់គ្នា កាលណោះការយើងវ៉ៃតាហាន លន់ នល់ គឺគាត់សុំធ្វើជាពួកម៉ាកមិត្តភ័ក្រ្តទៅដល់ពេលគាត់

ក្រោយពេលបែកភ្នំពេញ គាត់មានឋានៈជាអនុប្រធានវរៈខាងបើកបរជើងអាកាស ដល់គាត់ជួប ដល់ពេញជួបក៏ គាត់សំគេសខ្ញុំបានម៉ោពេញ៣ខែ រៀនបច្ចេកទេស ។

សុជាៈ ខាងអីដែរ?

លឿៈ ខាងសំណង់ព្រលានយន្តហោះ ។

សុជាៈ ព្រលានយន្តហោះ?

លឿៈ បាទរៀនបាន៣ខែ ខ្ញុំទៅប្រឡងបានចំណាប់ថ្នាក់លេខ២ បើនិយាយទូទាំងប្រទេសវាបានលេខ២ ត្រូវបានវិលទៅវិញនៅពេលនោះការងារត្រូវស្រោល ។

សុជាៈ យើងៗទៅធ្វើជាអ្នកជំនាញវិញ?

លឿៈ បាទ! ធ្វើជាអ្នកជំនាញ ហើយខ្ញុំបាននៅកន្លែងនោះជាអ្នកច្នៃថ្មី ក្រោយពេលដែលគេជីករើសតាមរើស កាប់ដើមគ្រាចងាប់ហើយ ចាក់ដីរឡូកិនកំណត់ហាប់ រួចហើយយកកែវយ៉ាយម៉ោយកម៉ោថ្មីង អត់មានការលំបាកប៉ុន្មានទេ ។

សុជាៈ អាហ្នឹងយើងដូចថា យើងសំណាងប៉ះជួបអ្នកយើងស្គាល់គ្នាហើយយើងចេះទៀត?

លឿៈ បាទ!

សុជាៈ បើសិនជាយើងអត់ចេះប្រហែលជាប្រឡូង?

លឿៈ ពិបាកដែរបាទ ។

សុជាៈ ប្រឡូងមិនបានដូច?

លឿៈ ប៉ុន្តែទម្រាំនឹងបានទៅដល់កន្លែងនេះ គឺឆ្ងងៗការលំបាកស្ទើរតែលាប់ស្ទើរតែមិនរស់ ។

សុជាៈ ទៅដល់ៗនៅកំពង់ឆ្នាំងមានចាប់គេចងទៀតទេ?

លឿៈ នៅមានទៀត បាទ ។

សុជាៈ នៅមានទៀត?

លឿៈ នៅតែមានហូហែរ បាទ អត់ដាច់ ។

សុជាៈ ហើយពូ ពូអីដែលជួបពូហ៊ានហ្នឹង គាត់ធ្វើការនៅព្រលាននៅកំពង់ឆ្នាំងតែម្តងឬក៏?

លឿៈ គាត់នៅពេញ ។

សុជាៈ នៅពេញទេ?

លឿៈ គាត់ទៅចុះយន្តហោះ ។

សុជាៈ គាត់ខាងបើកយន្តហោះអីដែរ?

លឿៈ បាទគាត់ទៅចុះយន្តហោះ នឹងខូចអញ្ចឹងគាត់ហៅទៅឲ្យជិតគាត់សួរគាត់ សួរវិលទៅវិញអត់និយាយអីទេ វិលទៅពេញវិញគាត់តេអូទៅ ។

សុជាៈ អាហ្នឹងគេប្រឡងអីហ្នឹង គេមុនប្រឡងគេមានបង្រៀនយើងទេដែរ?

លឿៈ បង្រៀន ។

សុជាៈ ខាងណាគេបង្រៀន ពួកណាគេបង្រៀន?

លឿៈ ពួកចិន ។

សុជាៈ ចិន?

លឿៈ ចិន ។

សុជាៈ ចិនម៉ោចិនចេះនិយាយខ្មែរអត់ទេស?

លឿៈ បកប្រែ ។

សុជាៈ មានអ្នកបកប្រែឲ្យ?

លឿៈ មានអ្នកបកប្រែបង្ហាត់បច្ចេកទេស ហើយមានសៀវភៅគេ គឺមានសៀវភៅបកប្រែឲ្យ ។

សុជាៈ បង្រៀនប៉ុន្មានថ្ងៃបានគេប្រឡង?

លឿៈ ៣ខែ ។

សុជាៈ ៣ខែ គេប្រឡង?

លឿៈ ៣ខែគត់បានប្រឡង ។

សុជាៈ ហើយអ្នកដែលដូរទៅបង្រៀន ទៅប្រឡងនឹងគេឈ្លាសវៃយ៉ាងម៉េចដែរ?

លឿៈ ហេះ!

សុជាៈ អ្នកដែលត្រូវដូចពូអញ្ចឹង ពូថាពូស្គាល់ពូហ៊ានហ្នឹងចុះអ្នកផ្សេងៗទៀត គេជ្រើសម៉ោនឹងគេជ្រើសតាមរបៀបម៉េច ដែលម៉ោប្រឡងនេះបាន?

លឿៈ មុនដំបូងខ្ញុំទៅដល់ភ្នំពេញ អានជាពួកម៉ាកនឹងគេថា ទៅរៀនតិចទៅចង់ចេះទៅរៀនឲ្យគេអើទៅរៀនទៅបច្ចេកទេសគេទៅបានទៅធ្វើការ ក៏គេបញ្ជូនឲ្យទៅរៀន ទៅរៀនអញ្ចឹងទៅការយកចិត្តពីគាត់ណាស់ ។

សុជាៈ បាទ?

លឿ៖ គេចេះអប់រំចិត្ត សតិអារម្មណ៍ខំប្រឹងរៀនៗ ទៅប្រឡងទៅក៏ស្រួលរកបាន ជាប់កងបាន បានចំណាប់ថ្នាក់ក៏វិលមកវិញ ធ្វើការនៅកំពង់ឆ្នាំងបណ្ដោយ ។

សុជា៖ កំពង់ឆ្នាំង?

លឿ៖ បាទ!

សុជា៖ នៅហ្នឹងធ្វើការហ្នឹង អ្នកណាគេអ្នកគ្រប់គ្រងធំនៅយើងកំពង់ឆ្នាំងព្រលានហ្នឹង?

លឿ៖ តាវៃ ។

សុជា៖ តាល្វៃ?

លឿ៖ បាទ! តាល្វៃ ។

សុជា៖ តាល្វៃចុះតាពីតាល្វៃហ្នឹង?

លឿ៖ ក្រៅពីរ ក្រៅមានច្រើនដែរ ហៅថាអ្នកបន្ទបន្ទប់ពីគាត់មក ។

សុជា៖ តាល្វៃ មានឈ្មោះច្រើនទៀតទេ?

លឿ៖ បាទ!

សុជា៖ ឈ្មោះផ្សេងទៀតទេ?

លឿ៖ ឈ្មោះបញ្ជីជាតិខ្ញុំមិនដឹងទេ ប៉ុន្តែស្គាល់គាត់នៅពេលនោះគឺ ឈ្មោះជាផ្លូវការជំនាន់នោះគឺ តាល្វៃ ហ្នឹងណាស់ ។

សុជា៖ គាត់ឋានៈជាយ៉ាងម៉េចដែរ?

លឿ៖ ប្រធានកងពលជើងទឹក ជើងគោក ជើងអាកាស ឃួងទាំងអស់ ។

សុជា៖ តាម៉េត?

លឿ៖ តាម៉េត ក៏នៅនោះដែរ ។

សុជា៖ តាម៉េត ឈ្មោះអីម៉េត?

លឿ៖ ទេខ្ញុំមិនស្គាល់នាមត្រកូលច្បាស់ហើយ ។

សុជា៖ តាម៉េត ណាតាល្វៃ ធំជាង?

លឿ៖ តាល្វៃ ។

សុជា៖ តាល្វៃធំជាង?

លឿ៖ ប្រធាន ។

សុជាៈ តាឡៃ មានគេចាប់ទេ?

លឿៈ មួយជំនាន់នោះខ្ញុំអត់ឃើញមានពីណាចាប់គាត់ទេណា ។

សុជាៈ បាទ?

លឿៈ ធ្វើការជាមួយគាត់រហូត ទល់នឹងនេះពេលដែលរដ្ឋ ថ្ងៃ៧ មករា នឹងក៏បែកគ្នាទៅ ។

សុជាៈ ចុះតាម៉េតៗ នឹងដែលឃើញគាត់ទេ?

លឿៈ ដែរ ។

សុជាៈ គាត់រាងរៅយ៉ាងម៉េចដែរ?

លឿៈ គាត់រាងខ្ពស់ស្តើង ។

សុជាៈ ស្តើង?

លឿៈ តាឡៃ ដុះពោះស្អុយ ។

សុជាៈ ស ឬ ខ្មៅតាឡៃ នឹង?

លឿៈ រាងស្តើង ស ។

សុជាៈ គាត់ឋានៈជាអីដែរ?

លឿៈ ឋានៈជាសមាជិក តាឡៃ ។

សុជាៈ សមាជិក តាឡៃ?

លឿៈ ដែលមានបន្ទាប់ម៉ោទៀតមានទាហាន ពីព្រោះតាឡៃ នឹងគឺជាសមាជិក ។

សុជាៈ ខាងតាឡៃ?

លឿៈ ខាងភស្តុភារដែរ រួចស្គាល់ច្បាស់ជាងគេ តែយាហែង នឹង តាឡៃ ព្រោះការងារត្រូវទាក់ទងនឹងគាត់ណា ។

សុជាៈ បាទ?

លឿៈ ខាងបច្ចេកទេស ។

សុជាៈ ហើយតាម៉េត សំម៉េតគាត់អាសាម៉ោកន្លែងព្រលានយន្តហោះ ហ្នឹងដែលតា?

លឿៈ មិនសូវ

សុជាៈ មិនសូវ?

លឿៈ បួនដប់ថ្ងៃឃើញគាត់ដើរម្តង ។

សុជា៖ ពេលគាត់ម៉ោដល់គាត់មើលគាត់សួរនាំអ្វីខ្លះដែរ?

លឿ៖ គ្រាន់តែសួរម៉េចហើយការងារ បានដំណើរការយ៉ាងណាៗ ព្រោះការថ្មើងដីសុទ្ធតែមានកត់នៅចំណុចណាៗ កត់ដល់ពេលគាត់មកជួនគាត់បើកមើលហ៊ីទៅ ។

សុជា៖ តាម៉េតគាត់ចេះក្បួនអស់ហ្នឹងដែរ?

លឿ៖ ប្រហែលជាចេះហើយបានគាត់មើលយល់ ។

សុជា៖ អ៎ហើយតាម៉េត ហ្នឹងមានដឹងថាគាត់ម៉ោពីខេត្តណា តំបន់ណា ភូមិភាគណាដែរ?

លឿ៖ ខ្ញុំមិនសូវស្គាល់ទេ ។

សុជា៖ តែគាត់ទីតាំងរបស់គាត់ មិនមែននៅក្នុងព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងជាប់ទេ?

លឿ៖ បាទគាត់នៅអត់ជាប់ប៉ុន្មានទេ ។

សុជា៖ គាត់ទៅពីភ្នំពេញទៅដែរ?

លឿ៖ ទៅភ្នំពេញទៅម៉ោៗ ។

សុជា៖ ពេលដែលគាត់ទៅម្តងៗ នឹងគាត់មានអង្គរក្សមានអីឆ្លកគាត់អមគាត់ទៅទេ?

លឿ៖ មាន ។

សុជា៖ មានដែរ?

លឿ៖ មានឡានហ្ស៊ីប២ទៅមុខក្រោយ ។

សុជា៖ អញ្ចឹងក្នុងពេលដែលពូ កំឡុងពេលដែលបានឃើញតាម៉េតអីតាហ្នឹង តាម៉េតហ្នឹងក្នុងពេលដែលឃើញតាម៉េតហ្នឹង មានការចាប់អ្នកនៅក្នុងអង្គភាពរបស់ពូ ពេលដែលតាម៉េតហ្នឹងឧបមាថា អាហ្នឹងកំឡុងពេលតាម៉េតគាត់គ្រប់គ្រងនៅហ្នឹង គាត់ជាសមាជិករបស់តាល្វៃនៅហ្នឹងអី?

លឿ៖ បាទ!

សុជា៖ មានដែលដឹងថា ជំនាន់ហ្នឹងមានការចាប់ខ្លួនអ្នកទៅធ្វើការនៅក្នុងក្រុងកងពូទៀតទេ?

លឿ៖ ក្រោយណោះដែលឃើញទៅក្រោយបីបួនថ្ងៃ បានឃើញ ។

សុជា៖ មានចាប់ទេ?

លឿ៖ មានចាប់ ។

សុជា៖ ចាប់ដោយមូលហេតុអីទេ ទៅដល់ហ្នឹងហើយ?

លឿ៖  សុទ្ធតែអត់ដឹងទាំងអស់ ។

សុជា៖  អត់ដឹងទាំងអស់?

លឿ៖  អត់ដឹងទោះបីជាលោកគ្រូក៏ដោយ  ខ្ញុំក៏ដោយគឺថា  គេហៅហើយគឺទៅបណ្តោយមិនអាចប្រកែកបានទេ ។

សុជា៖  មិនអាចប្រកែកថាអត់ខុសអី  អត់ត្រូវអីណេះ?

លឿ៖  វាអត់ដឹងថាអ្នកណាខុសអី  ត្រូវអីទេចាប់ ។

សុជា៖  ចាប់ទៅពូទៅ  ទៅធ្វើការហ្នឹងចិនខស្សាហ៍ចេញចូលញឹកញាប់ទេ?

លឿ៖  បាទ!  ដើរជាមួយគ្នាប៉ុន្តែមាននិយាយទំនាក់ទំនងការងារ  មានគេបកប្រែ ។

សុជា៖  មានគេបកប្រែ  ហើយកាលហ្នឹងគេបម្រុងធ្វើព្រលានយន្តហោះ  ទៅធ្វើជាព្រលានយ៉ាងម៉េចដែរ  ព្រលានយន្តហោះ?

លឿ៖  ខ្ញុំមិនយល់ព្រោះព្រលានគេនិយាយថា  រឿងដាក់យន្តហោះចម្បាំង ។

សុជា៖  ហើយគេធ្វើរៀបចំយ៉ាងម៉េច  នៅក្នុងព្រលានយន្តហោះហ្នឹង?

លឿ៖  នៅកាលខ្ញុំនៅធ្វើ  ព្រលានយន្តហោះហ្នឹងធ្វើទុកឲ្យហើយ  រដ្ឋប្រហារបណ្តោយណា ។

សុជា៖  បាទ?

លឿ៖  ប៉ុន្តែតាមតែដឹងមកទុកជាទីតាំងសម្រាប់ចម្បាំងពួកមានកន្លែងទម្លាក់យន្តហោះ  ទម្លាក់អីនៅភ្នំដីរីកូន  មានដីកកន្លែងទម្លាក់យន្តហោះហ្នឹង ។

សុជា៖  នៅមួយជួរខេត្តកំពង់ឆ្នាំងហ្នឹង?

លឿ៖  បាទប៉ុន្តែហេតុកាលគេ  សុំទៅមុខទៀតគេធ្វើយ៉ាងណា  គេខ្ញុំអត់ដឹងដែរ ។

សុជា៖  ពូអត់ដឹងដែរ?

លឿ៖  ហើយទទួលមុខសញ្ញាបច្ចេកទេសខុសគ្នាផង ។

សុជា៖  ចុះរូងភ្នំដាក់យន្តហោះហ្នឹង  ពូបានឃើញដែរ?

លឿ៖  បានឃើញមួយភ្លែតៗ ។

សុជា៖  គឺរូងធំដែរ?

លឿ៖  រូងធំជិះចូលទៅក្នុងចាក់  ចាក់រុនរូងក្រោយចូល ។

សុជា៖  ប៉ុន្មានដាក់ម៉ារូងហ្នឹង  អាចបានដាក់ប៉ុន្មានទៅ?

លឿៈ  មួយរុនៗអាចដាក់បាន៥ - ៦នាក់ ។

សុជាៈ  ច្រើនរុន?

លឿៈ  ច្រើនរុនដែរនៅក្នុងជំរំអណ្តូង ។

សុជាៈ  ហើយដល់ពេលដែលឡើងមករៀន  ឡើងមករៀននៅឯណាដែរ?

លឿៈ  នៅភ្នំពេញ ។

សុជាៈ  ម្តុំណានៅភ្នំពេញហ្នឹង?

លឿៈ  នៅខាងជើងវត្តភ្នំ  ខាងជើងឈៀងខាងកើតវត្តភ្នំហ្នឹង  កន្លែងហ្នឹងពីសង្គមចាស់គេហៅគេដាក់កន្លែងនាវាភាពយន្ត  នៅរៀននៅកន្លែងហ្នឹង ។

សុជាៈ  ពេលដែលពូធ្វើការនៅកំពង់ឆ្នាំង  ពូនៅធ្វើការរហូតដល់វៀតណាមចូល  ឬក៏មានផ្លាស់ប្តូរទៅណាទៀតទេ?

លឿៈ  អត់មានផ្លាស់ទៅណាទេនៅរហូតដល់ថ្ងៃ៧  មករា  ខ្ញុំគិតថាដំណើរជីវិតនេះលំបាកខ្លាំងណាស់  មើលទៅបើនៅមានដំណាក់នេះទៀតមើលទៅមិនអាចរស់បានទេ ។

សុជាៈ  ចុះពូទៅណាវិញ?

លឿៈ  ខ្ញុំគេចមកផ្ទះ  មកតាមគេតាមឯងរហូតមកជួបជុំឪពុកម្តាយនៅផ្ទះ ។

សុជាៈ  ចុះពូមកដល់ផ្ទះឆ្នាំណាខែណាដែរ?

លឿៈ  នៅខែ៦ឆ្នាំ៧៩ ។

សុជាៈ  ពូនៅជំនាន់ប៉ុល  ពត  ហ្នឹងតើមានដែលឃើញគេវ៉ៃវិហារសាសនា  វិហារសាសនាកាតូលិកទេ  ឬក៏វត្តអារាមយើង  វិហារយេស៊ូ,  វិហារចាមអី  តើពូមានដែលឃើញទេ?

លឿៈ  ឃើញ ។

សុជាៈ  ឃើញនៅណា?

លឿៈ  តែអង្គភាពខ្ញុំមិនដែលបានទៅវ៉ៃនិងគេទេណា ។

សុជាៈ  វ៉ៃនៅឯណា?

លឿៈ  ឃើញវ៉ៃវិហារកាតូលិកមួយនៅហ្នឹងខាងលិចអូរតែលវត្តភ្នំហ្នឹងណា  ខ្ញុំឃើញ ។

សុជាៈ  ពួកខាងណាវ៉ៃ?

លឿៈ  ពួកទ័ព ។

សុជាៈ កងពលណា?

លឿៈ នៅក្នុងកងពល៣១០ហ្នឹង ប៉ិនអគ្គភាពទ័ពវាខុសគ្នាណា ។

សុជាៈ គេវៃប៉ុន្មានខែ ប៉ុន្មានថ្ងៃ?

លឿៈ គេវៃរយៈប្រហែលជាជិតមួយខែ ។

សុជាៈ ពេលដែលគេវៃហ្នឹងពូនៅធ្វើការនៅឯណាដែរ?

លឿៈ ខ្ញុំនៅធ្វើការនៅក្បែរនោះដែរ ។

សុជាៈ នៅជាមួយតាគីម ហ្នឹង?

លឿៈ បាទ! នៅជាមួយតាគីម ។

សុជាៈ កាលហ្នឹងមិនទាន់ចាប់អឿន, ចាប់គីមហ្នឹងទេ?

លឿៈ នៅឡើយទេ ។

សុជាៈ ចុះមានពីណាគេជាអ្នកទទួលខុសត្រូវបញ្ជាអោយវៃហ្នឹងទេ?

លឿៈ គេនៅអគ្គភាពវរសេនាធំរបស់តាសាត ។

សុជាៈ ហើយក្នុងវរសេនាធំលេខប៉ុន្មានដែរ?

លឿៈ វរសេនាធំ៧៨ ។

សុជាៈ ហើយពេលដែលវៃហ្នឹងដូចថាមានអ្នកធំថ្នាក់ដឹកនាំប្រទេសណា ឬក៏ថ្នាក់កងពលណាគេទៅឈរមើលការនិងបញ្ជារការវៃនិងទេ?

លឿៈ អត់មានទេ ។

សុជាៈ មូលហេតុអីបានគេវៃវិហារនិងមានដឹងទេ?

លឿៈ មិនដឹងទេ ព្រោះផ្ទៃក្នុងគេអត់មានបញ្ជារអីអោយយើងហើយយើងក៏អត់ចង់ដឹងដែរព្រោះគេតឹងរឹង គេអោយយើងធ្វើអីធ្វើនិងទៅ ហើយខាងខ្ញុំគេអោយធ្វើស្រែឃ្លូច ដឹងតែព្រលឹម ឡើងនាំទ័ពចេញទៅធ្វើស្រែ អត់មានដឹងហើយអ្នកគ្រោះថ្នាក់នៅកន្លែងនោះក៏ច្រើនដែរ ។

សុជាៈ ហើយគេយកកម្ទេចកំទីនិងទៅណាដែរ?

លឿៈ យកទៅចោល ។

សុជាៈ ហើយគេប្រើអីវៃវិហារហ្នឹង?

លឿៈ  គេដាក់មីន ជាពិសេសដាក់មីន ដាក់មីនបុប្ផ ។

សុជាៈ  ពូដែលឃើញអ្នកធំអ្នកអីទេ ជំនាន់ប៉ុលពតមានដែលចូលរួមប្រជុំនយោបាយ ធ្វើមេទ័ពអី ជាមួយអ្នកធំ ឬក៏ធ្លាប់ទៅទទួលអ្នកធំ?

លឿៈ  ធ្លាប់បានទៅទទួល ។

សុជាៈ  ធ្លាប់បានទៅទទួលពីណាគេ?

លឿៈ  ទៅទទួលប៉ុល ពត, ខៀវ សំផន ហើយតាសុន សេនអី ។

សុជាៈ  ហើយទទួល ខៀវ សំផន ទៅទទួលនៅឯណា?

លឿៈ  ទទួលនៅធ្វើមេទ័ពនៅស្អាត គេទៅគេថាទៅធ្វើមេទ័ពទៅឈរទទួលគេ ។

សុជាៈ  កាលហ្នឹង ខៀវ សំផន ទៅដែរ?

លឿៈ  បាទ ។

សុជាៈ  ខៀវ សំផន មានឡើងនិយាយទេ?

លឿៈ  មិនសូវទេ កាលនិងប៉ុល ពត គេខទ្មែសនាម ។

សុជាៈ  ប៉ុល ពត និយាយថាម៉េចខ្លះ?

លឿៈ  និយាយតែពីរឿងតស៊ូវណ្ណៈ វណ្ណៈសក្តិភូមិ វណ្ណៈសក្តិភូមិវាមានស្តេចជាដើម ។

សុជាៈ  ហើយកាលហ្នឹងមិនសម្តេចគាត់ជាអ្នកបំផុសអោយទៅតស៊ូកាលហ្នឹង?

លឿៈ  បាទ! ។

សុជាៈ  ចុះម៉េចកម្ទេចវណ្ណៈនិងចោល?

លឿៈ  វណ្ណៈសក្តិភូមិខ្ញុំចេះតែឆ្ងល់យ៉ាងម៉េចចេះ តែមិនហ៊ាននិយាយអីទេ ។

សុជាៈ  ចុះមានវណ្ណៈណាទៀតដែលគេត្រូវកម្ទេចទៀតទេ?

លឿៈ  មានវណ្ណៈនាយទុន, វណ្ណៈអ្នកមាន ជាពិសេសអ្នកមានលើសគេគឺច្រើនតែកម្ទេចចោល សូម្បីតែនៅក្នុងជួរទ័ពហ្នឹងមានកូនអ្នកមានក៏គេដកចេញ តែគេមិនយកទៅសម្លាប់ទេគ្រាន់តែគេដកចេញពីជួរទ័ព ។

សុជា  ចុះខៀវ សំផន ពូមានដែលជួបគាត់នៅឯណាទៀតដែរទេ?

លឿៈ  ជួបនៅពេលដែលជំនុំធំៗហ្នឹង ។

សុជាៈ  គាត់មាននិយាយទេ?

លឿៈ អត់មានទេ ។

សុជាៈ ចុះក្រៅពីខៀវ សំផន?

លឿៈ តាសុន សេន ចេញសេចក្ដីប្រកាសចរាចរណ៍អី ចេញពីតាសុន សេន ។

សុជាៈ សុន សេន ច្រើនជាចេញសេចក្ដីប្រកាសចរាចរណ៍អីខ្លះ?

លឿៈ ចរាចរណ៍ប្រកាសណែនាំទ័ពអី ខំធ្វើការអីនិយាយដូចជាប៉ុល ពត ។

សុជាៈ ប៉ុល ពត អញ្ចឹង?

លឿៈ និយាយដូចគ្នាប៉ុន្តែគាត់មិនដែលនិយាយផ្ទាល់ ។

សុជាៈ បាទ?

លឿៈ តាំងពីដឹកស្រះ ។

សុជាៈ ផ្សេងប្រកាសមក?

លឿៈ បាទ!

សុជាៈ ហើយកាលហ្នឹង ខៀវ សំផន គាត់មានឋានៈអីដែរ?

លឿៈ អនុប្រធានរដ្ឋ ។

សុជាៈ អនុប្រធានរដ្ឋអាណឹងពេលគេទៅចូលប្រជុំទៅប៉ុល ពត, ខៀវ សំផន, នួន ជា, ស៊ុន សេន អីគេនៅចូលអង្គុយម៉ាកន្លែងគ្នាគេទៅណេះ?

លឿៈ បាទ!

សុជាៈ ចុះដូចជា តាម៉ុក អីដែរឃើញទេ?

លឿៈ ឃើញដែរកាលហ្នឹង ។

សុជាៈ ចុះពូមានបានរៀននយោបាយដូច ថាពួកហ្នឹងចុះទៅបង្រៀនទៅដល់កន្លែងមូលដ្ឋានរបស់មុនអង្គភាពមុនដែរមានទេ?

លឿៈ រៀនៗដែលកងពលបង្ហាត់បណ្ដោយ ។

សុជាៈ ចុះដល់ពេលគេចាប់អឿន គេមានដែលគេមានដែលទៅប្រជុំ បំពាក់បំប៉ននយោបាយយើងបង្ហាញប្រាប់ថា អឿន ក្បត់ដោយសារមូលហេតុអីមួយខាងអី?

លឿៈ មានលោកគ្រូមាន ក្រោយចាប់តាអឿន, តាគឹម, តាយៀក គណៈកងពលរួចហើយនេះ គេហៅវរសេនាធំទៅទៀត ក្រោយគេហៅវរធំទៅហើយតាទៅបាត់ហើយ បានហៅមួយ

សារពួកខ្ញុំហ្នឹងពួកសំណាក់វរៈអីទៅ ទៅដល់មុនដំបូងគេឆែកអញ្ចឹងទៅៗ មានកាំភ្លើងមានអី កាលនោះគេមិនប្រើកាំភ្លើង កាំភ្លើងខ្លីកាំភ្លើងអីគេដកទុកអញ្ចឹងទៅ ណាមានដែកកេះ មាន លាមអីដកដូចជាមុនៗអញ្ចឹង ស្រាប់ទៅដល់ចូលសាលាគេមាន ខទ្ទេសនាមហើយគេចាក់ ខ្សែរអាត់ឲ្យស្តាប់ ខ្សែរអាត់នឹងដូចខ្សែរអាត់ តាគឹម, តាអឿនបានដឹងអញ្ចឹង ។

សុជា: គេចាក់ស្តាប់នឹងគេនិយាយថាម៉េចខ្លះ?

លឿ: គេនិយាយពីប្រវត្តតាំងពីបដិវត្តតស៊ូនៅឆ្នាំ ប៉ុន្មានៗអីទេរហូតមកក្បត់ហ្នឹងនៅពេលណាៗ ទៅដឹក ។

សុជា: ពីណាគេចុះអារឿងទាក់ទងជាមួយនឹងកាលដែរ ជាមួយតានេះកាលមុន?

លឿ: តាសំបូរ ។

សុជា: មានគេមានព្កគេនិយាយទេ?

លឿ: អត់មានទេ ។

សុជា: អត់ព្កដែរ?

លឿ: បាទតាសំបូ គេចាប់ទុកគេបាញ់គាត់នៅក្នុងជម្រកចំលេងមានពីណាហ៊ាន ។

សុជា: អត់មានទាក់ទងអីទេ?

លឿ: អត់មាន ។

សុជា: ម៉ោៗជាមួយអឿន មួយអីទៀតទេ?

លឿ: បាទ!

សុជា: ចុះពេលហ្នឹងអឿន រៀបទ័ពបំរុងវ៉ៃនេះមែន ឬក៏គ្រាន់តែពាក្យចចាមអារាមទេ?

លឿ: វ៉ៃភ្នំពេញ ។

សុជា: បាទ?

លឿ: កាលរៀបទ័ពគឺមានប្រកត់ ដាក់មែន ។

សុជា: ចុះពូមានបានដឹងរឿងហ្នឹងដែរ?

លឿ: ប៉ុន្តែខ្ញុំគេឲ្យរៀបទ័ដែរ រៀបចំស្បៀងគេថារៀបចំកាំភ្លើង រៀបចំទ័ពក្រវីកាំភ្លើងមើល ទៅគេអោយរៀបចំ ដល់ពេលដែលត្រូវវ៉ៃឬមិនត្រូវវ៉ៃ ដល់ពេលគេហៅគាត់ទៅ

បាត់ទៅក៏មិនដឹងម៉េច បើមេក្បត់ហើយមិនដឹងជាមានអី ដល់ពេលដោះខ្លួនទៅបានដឹងថាមេក្បត់មែន ហើយនៅក្នុងចង្កោមវរសេនាតូចទាំងអស់គ្នាហ្នឹងអស់ច្រើន ។

សុជាៈ ចុះពូមានដែលឃើញគេធ្វើទារុណកម្មមនុស្សផ្ទាល់ទេ កាលពីជំនាន់ហ្នឹង?

លឿៈ ឃើញខ្លះដែរ ។

សុជាៈ ឃើញនៅឯណា?

លឿៈ ឃើញនៅពេទ្យកាល់ម៉ែត គេនៅមួយកន្លែងដំបូងគេយកមកដាក់នៅកន្លែងហ្នឹង យកមកពីកន្លែងណាៗក៏ដោយក៏គេយកមកដាក់នៅកន្លែងហ្នឹង ។

សុជាៈ ខ្មែរយើងតើដែលគេយកមកដាក់នៅកន្លែងហ្នឹង?

លឿៈ ខ្មែរ ។

សុជាៈ ចុះមានបរទេសទេដែលគេយកមកដាក់នៅកន្លែងហ្នឹង?

លឿៈ មិនឃើញទេ ព្រោះកាលដែលដាច់ភ្នំពេញខ្ញុំមិនទាន់បានទៅដល់ទេណា ដល់ពេលដែលខ្ញុំទៅវាអត់ឃើញមាននៅសល់ ។

សុជាៈ អស់ហើយ?

លឿៈ បាទ! អស់ហើយ ។

សុជាៈ ចុះខ្មែរដែលគេយកទៅដាក់និងមានរឿងអីដែរ?

លឿៈ ខ្មែរនិងឃើញតែទ័ពគ្នាឯងនិងទៀតណាដែលចាប់ទៅហ្នឹង ។

សុជាៈ ហើយពូធ្លាប់ឆ្លងកាត់របបខ្មែរក្រហមចឹង តើមានគេមកសួរនាំប្រវត្តិរូបពូទេ?

លឿៈ ធ្វើ ។

សុជាៈ គេធ្វើគេសួរយ៉ាងម៉េចខ្លះ?

លឿៈ មុនដំបូងគេសួរចេះ ថាយើងមានឪពុកឈ្មោះអីម្តាយឈ្មោះអីមានបងប្អូនប៉ុន្មាននាក់ អាប្រវត្តិរូបពិស្តារនោះផ្សេងទៀតទៅ ។

សុជាៈ គេមានថតរូបថតអីទេ?

លឿៈ អត់មានទេ ។

សុជាៈ កាលដែលគេចាប់ពួកយុទ្ធជនដែលគេចាប់ដាក់មន្ទីរពេទ្យកាល់ម៉ែត្រហ្នឹង តើពួកគេមានកំហុសអីខុសឆ្គងអី?

លឿ៖ សុទ្ធតែគ្មាន ។

សុជា៖ សុទ្ធតែខ្មែរៗយើង?

លឿ៖ សុទ្ធតែខ្មែរហើយសុទ្ធតែទ័ពទៀត ហើយពួកទ័ពអត់មានប្រឡូកជាមួយប្រជាជនទេ ។

សុជា៖ ពូទៅធ្វើអីនៅហ្នឹង?

លឿ៖ កន្លែងខ្ញុំនៅជិតហ្នឹង ។

សុជា៖ កន្លែងមន្ទីរពិការហ្នឹង?

លឿ៖ នោះឯង នៅទល់មុខហ្នឹង ។

សុជា៖ ពូធ្លាប់បានឆ្លងកាត់របបខ្មែរក្រហមមកចឹង តើពូថារបបនិងវាយ៉ាងម៉េចដែរ?

លឿ៖ បើនិយាយពីរបបនេះវាប្រល័យពូជសាសន៍ សំលាប់តែគ្នាឯងនិងវាប្រល័យពូជសាសន៍ទៅហើយ រកថាយ៉ាងម៉េចទៅកើត ។

សុជា៖ ចុះមានដឹងថានៅកន្លែងណាដែលមានចំនុចល្អទេ នៅក្នុងរបបហ្នឹងការគ្រប់គ្រងរបស់គេ?

លឿ៖ អាចថាមានខ្លះដែរ ។

សុជា៖ មានអីខ្លះទៅ?

លឿ៖ គេអោយយើងប្រឹងធ្វើការ ទៅវាបានប្រយោជន៍ កុំតែសំលាប់មនុស្សវាមានអី ។

សុជា៖ ពូមានដែលសុំគេមកលេងផ្ទះទេ?

លឿ៖ សុំតែគេអត់អោយមក ។

សុជា៖ ហើយក្រោយ៧៩មកមានពីណាគេមកសួរនាំពូចឹងទេ?

លឿ៖ អត់មានទេ ។

សុជា៖ ចឹងដូចមានខ្ញុំមកសួរនាំពូចឹង តើពូមានអារម្មណ៍យ៉ាងម៉េចដែរ?

លឿ៖ មានអារម្មណ៍យ៉ាងម៉េច ។

សុជា៖ អត់ភ័យទេ?

លឿ៖ អត់ភ័យអត់ស្លុត អត់ខ្លាចយកទៅណាទេ ។

សុជា៖ ពូមានដែលនិយាយរឿងរ៉ាវដូចនិយាយប្រាប់ខ្ញុំហូរហែរមកចឹង ប្រាប់កូនចៅពូអោយបានដឹងទេ?

លឿ៖ និយាយប្រាប់ ។

សុជាៈ ហេតុអីបានពូនិយាយប្រាប់?

លឿៈ (ស្តាប់អត់បាន) ។

សុជាៈ ចុះពូគិតថារឿងរ៉ាវនិងគួរតែបំភ្លេចចោលឬក៏ប្រាប់ក្មេងៗអោយបានដឹងតទៅទៀត?

លឿៈ ពូគិតថាគួរតែបំភ្លេចវាចោលដើម្បីកសាងជីវិតថ្មី ព្រោះសព្វថ្ងៃវា វាថ្មីទៅហើយវានៅក្នុងក្មេងប៉ុនណេះវាស្គាល់ចានស្គាល់អញ្ចឹងហើយ ។

សុជាៈ បាទចុះពូអើមានបងប្អូនស្លាប់ណេះនៅក្នុងរបប ប៉ុល ពត ហ្នឹងឪពុក ម្តាយ របស់បងប្អូនឬអីក៏?

លឿៈ បងប្អូនគ្មាន ។

សុជាៈ ចុះឪពុក ម្តាយ?

លឿៈ ឪពុក ម្តាយក៏អត់ដែល ។

សុជាៈ ចុះពូរាល់ថ្ងៃដែលលឺពីរឿងរ៉ាវគេបំរុងបង្កើតតុលាការ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមពូដែលលឺទេ?

លឿៈ ខ្ញុំមិនដែលបានស្តាប់រ៉ាដ្យូអីគេទេ អត់មាន ។

សុជាៈ ពូយល់យ៉ាងម៉េចដែលបើសិនគេកាត់មេដឹកនាំខ្មែរក្រហម?

លឿៈ បាទ គេកាត់ៗ ។

សុជាៈ ពូគិតថាការកាត់ទោសហ្នឹងវាមានសារៈសំខាន់អីដែរ?

លឿៈ មិនទាន់យល់ទេបាទ ។

សុជាៈ មិនទាន់យល់ទេ?

លឿៈ ថ្មីៗនេះខ្ញុំមិនហាននិយាយ ព្រោះខ្ញុំអត់យល់ព្រោះខ្ញុំមិនបានស្តាប់ ។

សុជាៈ ហើយបើតាមការកាត់ទោសហ្នឹង តាមគំនិតពូគួរយកមេដឹកនាំត្រឹមថ្នាក់ណាទៅកាត់ទោសត្រឹមកំរិតណាដែរ?

លឿៈ វាអស់ហើយត្រឹមថ្នាក់កងពល វាអស់របត់ហើយ ។

សុជាៈ កងពលឡើងទៅលើ?

លឿៈ បាទត្រឹមកងពលឡើងទៅលើ ។

សុជាៈ ហេតុអីមិនបានយកអ្នកក្រោម អើបើអ្នកដៃដល់?

លឿៈ ផ្ទាក់ក្រោមសុទ្ធតែក្រោមការដឹកនាំរបស់គេ ព្រោះគេបញ្ជារបស់គេខ្ញុំមិនដឹងធ្វើម៉េច ។

សុជាៈ ចុះពូយល់យ៉ាងម៉េចដែលថាពាក្យថាយុត្តិធម៌ពូ ពូយល់យ៉ាងម៉េចដែលពាក្យថាយុត្តិធម៌ពូ?

លឿៈ អើពាក្យថាយុត្តិធម៌ យុត្តិធម៌គឺនឹងរកយុត្តិធម៌ដើម្បីថាសង្គ្រោមមនុស្ស ។

សុជាៈ បាទៗ អញ្ជឹងពូអរគុណច្រើន ពូមានអីដែលខ្ញុំមិនបានសួរពូដែរ?

លឿៈ អត់មានអីទេ ។

សុជាៈ អញ្ជឹងអរគុណពូច្រើនពូណាស់ ។

យើងបានសម្ភាសជាមួយនឹងលោកពូឈ្មោះកែវ លឿ នៅភូមិអើជាំផល ឃុំមានជ័យ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ហើយ តាមការសម្ភាសន៍នេះ យើងឃើញថាយើង បានដឹងរឿងមួយដែលបន្ថែមពីរឿបរបស់ ពូសឹយ, អ៊ឹម សឹយ ដែលយើងបានសម្ភាសន៍នៅភូមិចុងដា ឃុំត្បូងក្រពើ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ដែលស្រុកសន្ទុក ស្រុកស្ទឹងសែន ខេត្តកំពង់ធំ អំពីរឿងការបាញ់សម្លាប់របស់ ឈ្មោះអើ សំបូ ដែលជាឋានៈវរៈ នៅក្នុងកងពល៣១០ ទាក់ទងរឿងដែលសំបូ នេះផ្តល់ព័ត៌មានទៅឲ្យ លន់ នល់ វ៉ៃ ទព័ប៉ុល ពត នៅម្តុំភូមិរលួស ត្រង់នេះគាត់និយាយដូចគ្នាទៅនឹងពូ សឹយ ដែលនិយាយប្រាប់យើងកាលពីលើកមុន ហើយនេះហើយជារឿងយើងអាចជារឿងពិតមួយ ហើយពូបានដឹងថាគេបាញ់ ពូផ្ទាល់ក៏បាន ឡើងឋានៈទៅជាអនុវរៈជំនួសតាគឹម ។ តាគឹម គឺជាអ្នកបាញ់សម្លាប់ អើឈ្មោះសំបូ គឹមនឹងមុនដំបូងគឺជាអនុវរៈ ៣១៧ ដល់ពេលដែលគេដឹងថាសំបូ នឹងក្បត់ក៏គេឲ្យតាគឹម នឹងទៅបាញ់សម្លាប់សំបូ ហើយគឹមបានឡើងទៅជាឋានៈប្រធានវរៈ៣១៧ហ្នឹង ឲ្យពូផ្ទាល់ឈ្មោះពូលឿ នេះក៏បានឡើងទៅជាអនុប្រធាន តែហើយបានទៅសួរថាតើការបាញ់របស់គាត់ បាញ់សម្លាប់សំបូ ហ្នឹងទាក់ទង ទៅនឹងរឿងរបស់អើតាអឿន គាត់មិនបានដឹងទេ ព្រោះគាត់ពេលដែលបែក៧៥ ហើយគឺគាត់ត្រូវរបួសគាត់បានមកសម្រាកពេទ្យនៅអូរក្រវ៉ាន់ ហើយដល់ខែ៦ ដែលគេរៀបចំមនុស្សជិតអស់បានគាត់ចុះទៅពេលនោះគាត់ទៅជាកងពិការ នៅក្នុងកងពិការហើយគេបានបញ្ជូនគាត់ ឲ្យទៅធ្វើការធ្វើស្រែនៅខ្ទញកប់ស្រូវនៅក្រៅក្រុង ដូច្នេះរឿងរ៉ាវ នៅបន្ទាប់ពីហ្នឹងម៉ោគាត់មិនសូវបានដឹងច្រើន ហើយរឿងថ្មីមួយទៀតទាក់ទង គឺរឿងសម ម៉េតគឺ គាត់បានស្គាល់ឈ្មោះ ម៉េត គាត់មិនបានប្រាប់រឿងថាឈ្មោះ សម ម៉េត ទេតែគាត់ស្គាល់ថា ម៉េត ហ្នឹងគឺជាអ្នកគ្រប់គ្រងមួយជាសមាជិកមួយក្រោមការគ្រប់គ្រងរបស់តាល្វៃ នៅឯខេត្តកំពង់ឆ្នាំងព្រលានយន្តហោះ ខេត្តកំពង់ឆ្នាំង ហើយ

បើបានទាក់យើងមិនបានព្យាយាមសួរគាត់ថាតើម៉ែត ហ្នឹងឈ្មោះអី ម៉ែត មានឋានៈអីៗគឺគាត់មិនបានដឹង មិនដឹងពិតប្រាកដទេ គ្រាន់ដឹងថាឈ្មោះ ម៉ែត ហ្នឹងគឺជាថ្នាក់អ្នកគ្រប់គ្រងមួយនៅក្នុងក្នុងអើកងទ័ពអាកាស ក្រោមបញ្ជារបស់តាល្វៃ នេះ អ្នកបង្ហាញថាគាត់ហ្នឹងបានស្គាល់អើតាម៉ែតត្រូវជាថ្នាក់ដឹងនាំរបស់ ប៉ុល ពត នៅក្នុងជំនាន់របប ហ្នឹងរបបខ្មែរក្រហមហ្នឹង ។